ព្រះរាជាណាចក្រកម្ពុជា

**KINDOM OF CAMBODIA**

ជាតិ សាសនា ព្រះមហាក្សត្រ

**Nation Religion King**

# <u>កិច្ចព្រមព្រៀងសះជាលើករណីដីចម្ការតាមដងអូរ</u>
# <u>របស់សហគមន៍ភូមិពូលុជាមួយក្រុមហ៊ុនសេដ្ឋិកុលា</u>

# <u>Settlement Agreement on Land Along the Stream of Pu Lu Village with Sethikula Company</u>

កិច្ចព្រមព្រៀងនេះធ្វើនៅស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី, នាថ្ងៃទី២១. ខែ.កញ្ញា... ឆ្នាំ២០២១

This Agreement is entered into Pichreada District, Mondulkiri province, on the.21st...Sep. 2021

**រវាង**

**Between**

ភាគីតំណាងសហគមន៍លើករណីដីចម្ការតាមដងអូររបស់សហគមន៍ភូមិពូលុ រួមមាន៖

The community party representing the land along the stream Pu Lu village includes:

១). ឈ្មោះ **មើល ង៉ែវ** ភេទ ប្រុស កើតឆ្នាំ [redacted] មានតួនាទីជា តំណាងចាស់ទុំ-សមាជិកសហគមន៍

1). Moeurl Ngev , male, born in [redacted], as the Elderly and community member representative

២. ឈ្មោះ ព្យើល នៀន ភេទ ស្រី កើតឆ្នាំ [redacted] មានតួនាទីជា តំណាងសហគមន៍

2. Pyoeurl Nien, female, born in [redacted], as the Leader of community

៣. ឈ្មោះ **ម៉ាលី គីម** ភេទ ប្រុស កើតឆ្នាំ [redacted] មានតួនាទីជា តំណាងត្រីភាគី

3. Maly Kim, male, born in [redacted] as the Head of the tripartite committee;



first class

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sophe[illegible], Translation PM [illegible] Kruy, CEO

មានទីលំនៅបច្ចុប្បន្ននៅភូមិពូលុ ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ហៅកាត់ថា **"ភាគីសហគមន៍"**

Currently residing in Pu Lu village, Busra commune, Pichreada district, Mondulkiri province, referred to as **"The Community Party"**

**ក្រុមហ៊ុន សេដ្ឋិកុលា** តំណាងដោយលោក[redacted]កើតឆ្នាំ[redacted] ឆ្នាំ កាន់លិខិតឆ្លងដែនលេខ [redacted] ចុះថ្ងៃទី[redacted] ចេញឱ្យដោយប្រទេស[redacted] និង កញ្ញា[redacted] កើតឆ្នាំ [redacted]កាន់លិខិតឆ្លងដែនលេខ[redacted]ចុះថ្ងៃទី[redacted] ចេញឱ្យដោយប្រទេស[redacted] មានអាសយដ្ឋានក្រុមហ៊ុនស្ថិតនៅ ផ្ទះលេខ[redacted] ផ្លូវលេខ[redacted] ក្រុម[redacted] ភូមិ[redacted] សង្កាត់[redacted] ខណ្ឌ[redacted] ដែលជាភាគីវិវាទ ហៅកាត់ថា **ភាគីក្រុមហ៊ុន**។

**Sethikula Co., Ltd.** represented by[redacted], born in[redacted], holding Passport No[redacted]issued on[redacted] by[redacted] and [redacted], born in[redacted], holding Passport No.[redacted] issued on[redacted] by[redacted], with the company's address at House,[redacted] street[redacted], group[redacted], village[redacted] quarter,[redacted] district,[redacted] as disputing party hereinafter referred to as **"The Company Party"**;

**ភាគីទាំងអស់ បានព្រមព្រៀងគ្នាដូចតទៅ៖**

**The Parties have agreed to the following:**

## ប្រការ ១.- កម្មវត្ថុនៃកិច្ចព្រមព្រៀង

**Article 1.- Subject of the Agreement**

ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាលើចំណុចសះជា មួយចំនួនរួមគ្នាដូចខាងក្រោមនេះ៖

**The Community Party** and **the Company Party** agree and approve the common settled issues as below:

### ១.១.- ការចុះបញ្ជីដីចម្ការតាមដងអូរ ជាដីរួមសហគមន៍

### 1.1.- Registration of land along the stream as Communal land

- ភាគីសហគមន៍ ព្រមព្រៀងធ្វើការដាក់ពាក្យសុំចុះបញ្ជីដីតាមដងអូរទាំងអស់ជាដីរួមសហគមន៍។ នៅពេលមានការចុះបញ្ជីដីចម្ការតាមដងអូរជាដីរួមរបស់សហគមន៍។



first class
**First-Class Solutions Ltd.,** registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia
#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*
Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*
**CHAN Sophea**, Translation PM / **LIM Kruy**, CEO
FIRST-CLASS SOLUTIONS LTD

- **The community Party** agrees to apply for registration of all farmland along the stream as community land. When there is a land registration of farmland along the stream as communal land.
- ភាគីក្រុមហ៊ុន នឹងមិនធ្វើការទប់ស្កាត់ ឬរំខានដល់ដំណើរការចុះបញ្ជីរបស់ក្រុមបញ្ជីដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជាឡើយនៅពេលមានការចុះបញ្ជីដីរួមសហគមន៍សម្រាប់សហគមន៍ភូមិពូលុ ។ ប្រសិនបើដីចម្ការតាមដងអូរដែលយកមកធ្វើការសម្រុះសម្រួលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) រួចហើយ ភាគីក្រុមហ៊ុនស្នើសុំធ្វើការផ្ទេរទៅជាប័ណ្ណដីរួមសហគមន៍វិញ។ ប៉ុន្តែភាគីសហគមន៍មិនត្រូវយកទីតាំងដីចម្ការដែលជាន់គ្នាជាមួយចម្ការកៅស៊ូ ក្រុមហ៊ុនទៅចុះបញ្ជីឡើយ។ ដរាបណាដីចម្ការមិនទាន់បានចុះបញ្ជីដីធ្លីជាផ្លូវការជាមួយក្រសួងពាក់ព័ន្ធ ភាគីក្រុមហ៊ុននឹងបន្តចាត់ទុកថាជាដីចម្ការខុសច្បាប់ ហើយរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច។
- **The Company Party** would not block or interfere with the land registration process of the land registration team from the Royal Government of Cambodia when registering community farmland for Pu Lu village. If the farmland along the stream under the mediation process already has an ownership certificate (hard title deed), the **Company Party** requests that it would be transferred to communal land title. But the **Community Party** shall not register the overlapping area with the rubber plantation of the company. As long as the farmland is not officially registered with the relevant ministries, **the Company Party** will continue to consider them as illegal farmland and report them to the relevant authorities.

### ១.២.- ករណីបាត់បង់ផលដំណាំរបស់ភាគីសហគមន៍ និងភាគីក្រុមហ៊ុន

### 1.2. The case of crop loss of the Community Party and the Company Party

- ភាគីក្រុមហ៊ុនធានាថានឹងមិនប៉ះពាល់ដំណាំផ្សេងៗរបស់សហគមន៍ឡើយ ។ ភាគីក្រុមហ៊ុនឯកភាព ធ្វើការអប់រំ និងណែនាំដល់កម្មកររបស់ក្រុមហ៊ុនទាំងអស់ មិនឲ្យធ្វើការប៉ះពាល់ដំណាំផ្សេងៗរបស់សហគមន៍

  ឡើយ។
- **The Company Party** warrants that it will not affect the crops of the community. **The company Party** agrees to educate and advise all company workers not to harm the community's crops.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

**CHAN Sopheap**, Translation PM **LIM Kruy**, CEO

- ភាគីក្រុមហ៊ុនត្រូវការ ការចូលរួម និងសហការផ្តល់ព័ត៌មានពី ភាគីសហគមន៍ ហើយនឹងធ្វើការស៊ើបអង្កេត មុនពេលមានការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ដែលបានប៉ះពាល់ផលកៅស៊ូរបស់ក្រុមហ៊ុន ។
- **The Company Party** needs the involvement and cooperation of the Community Party and will investigate the losses of company's rubber before accusing anyone of affecting the company's rubber.
- ភាគីសហគមន៍ឯកភាព ធ្វើការអប់រំ និងណែនាំដល់សមាជិករបស់ខ្លួនកុំឱ្យប៉ះពាល់ផលកៅស៊ូរបស់ក្រុមហ៊ុន។
- **The Community Party** agrees to educate and advise its members not to affect the company's rubber.

**១.៣- ការឈូសឆាយដីចម្ការតាមដងអូរ និងការរានពង្រីកដីថ្មីតាមដងអូរ**

**1.3.- The clearance of farmland along the stream and clearing new lands along streams**

- ប្រសិនបើថ្ងៃក្រោយ ភាគីក្រុមហ៊ុន ធ្វើការកាយស្តារប្រឡាយក្រុមហ៊ុនដែលអាចនឹងប៉ះពាល់ដីចម្ការតាមដងអូររបស់សហគមន៍ ភាគីក្រុមហ៊ុនត្រូវជូនដំណឹងជាមុនទៅភាគីសហគមន៍ ឬសមាជិកសហគមន៍ដែលមានដីចម្ការនៅក្បែរទីតាំងប្រឡាយដែលត្រូវស្តារនោះ។
- In the future, if **the Company Party** restores of the company drains that could affect the community farmland along the stream, **the Company Party** shall notify in advance to **the Community Party** or community members who have farmland located near the drains to be restored.
- ភាគីក្រុមហ៊ុនសូមធ្វើការធានាថាមិនធ្វើការប៉ះពាល់ ឬឈូសឆាយដីតាមដងអូរ ឬដីដែលជាតំបន់ការពារបរិស្ថានទេ។
- The **Company Party** warrants that it will not affect or clear the farmland along streams or lands in protected areas.
- សហគមន៍យល់ព្រម មិនធ្វើការកាប់រានពង្រីកដីតាមដងអូរយកទៅធ្វើជាចម្ការបន្ថែមទៀតទេ
- **The Community Party** agrees not to clear additional land along streams to be used as farmland.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fclnfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

**CHAN Sopheap**, Translation PM **LIM Sruy**, CEO

- ក្នុងករណីមានការកាប់ឆ្ការព្រៃក្នុងដីចម្ការចាស់តាមដងអូរដែលបានវាស់វែងរួចសម្រាប់ការសម្រុះសម្រួល តែដីចម្ការនោះត្រូវបានទុកចោលដោយមិនមានការដាំដុះ ក្រុមហ៊ុននឹងរក្សាការជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធ ព្រោះដីចម្ការនោះមិនទាន់មានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) និងមិនទាន់មានការទទួលស្គាល់ជាកម្មសិទ្ធិរបស់

  សហគមន៍ពីរដ្ឋាភិបាលនៅឡើយ។
- In case of clearing existing farmland along the stream which has already been measured for mediation but the farmland is left uncultivated, the company will keep notifying to the relevant authorities because the farmland does not have ownership certificate (hard title deed) and has not yet been recognized as community ownership by the government.
- ភាគីសហគមន៍ នឹងយល់ព្រមធ្វើការដោះស្រាយជាមួយអាជ្ញាធរមានសមត្ថកិច្ចដោយខ្លួនឯង ក្នុងករណីមានបណ្ដឹង ឬការហាមឃាត់មិនឲ្យពង្រីកចម្ការតាមដងអូរពីភាគីក្រុមហ៊ុន។
- The **Community Party** agrees to settle with the competent authorities themselves, in the event of any complaint or prohibit from the expansion of farmland along the stream from **the Company Party**.

### ១.៤.- ការកាប់រានដីថ្មី តាមរយៈការស្នើសុំទៅអាជ្ញាធរភូមិ

### 1.4- Clearing new land by requesting village authority

- ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រមថា ករណីកាប់រានដីតាមដងអូរថ្មី តាមរយៈការស្នើសុំទៅអាជ្ញាធរភូមិ ត្រូវបញ្ឈប់ ដោយហេតុថាអាជ្ញាធរភូមិ ឬមេភូមិ មិនមានសិទ្ធិអនុញ្ញាតឲ្យសហគមន៍ធ្វើការកាប់រានដីតាមដងអូរយកធ្វើជាចម្ការថ្មីទេ ប្រសិនបើមានការកាប់រានដីតាមដងអូរយកធ្វើជាចម្ការថ្មីកើតឡើងនៅក្នុងដែនសម្បទានដីរបស់ក្រុមហ៊ុន នោះភាគីក្រុមហ៊ុនមានកាតព្វកិច្ចជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធ។
- **The Community Party** and **the Company Party** agree that the clearing of new land along the stream by requesting the village authority shall be stopped because the village authority or village chief does not have the right to allow the community to clear land along the stream as new farmland. If clearing of land along streams for new farmland occurs within the company's land concession, **the Company Party** has the obligation to notify the relevant authorities.



**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia
#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*
Phnom Penh, September 17, 2021
*This is to certify that this translation faithfully corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*
CHAN Sopheap, Translation PM [illegible] Kruy, CEO

## ១.៥- ពេលវេលាដុតព្រៃក្នុងចម្ការ

## 1.5.- Time for burning the shrub/bush inside the farmland

ភាគីក្រុមហ៊ុន និងភាគីសហគមន៍ព្រមព្រៀង៖

**The Company Party and Community Party agree:**

- សមាជិកសហគមន៍ដែលមានគម្រោងដុតព្រៃក្នុងចម្ការ ត្រូវរាយការទៅក្រុមហ៊ុនជាមុន ដើម្បីក្រុមហ៊ុនមានពេលរៀបចំបុគ្គលិកសម្រាប់ការពារភ្លើងឆេះព្រៃ ឬចម្ការកៅស៊ូរបស់ក្រុមហ៊ុន ចម្ការរបស់អ្នកដទៃ និងកុំឲ្យជាន់ពេលវេលាកំណត់ដុតព្រៃក្នុងចម្ការជាមួយសហគមន៍ដទៃទៀត។
- Community members who plan to burn farm bushes must report to the company in advance so that the company can easily organize workers to protect the company's rubber plantations and others' plantations from the fire, and not to be overlapped with other communities' burning time.
- ការរៀបចំដុតព្រៃក្នុងចម្ការត្រូវធ្វើឲ្យបានមុនពេលចូលឆ្នាំខ្មែរ។
- Arrangements for burning farm bushes must be made before the Khmer New Year.
- ការដុតព្រៃក្នុងចម្ការត្រូវចាប់ផ្ដើមយ៉ាងយឺតបំផុតត្រឹមម៉ោង ៩ និង ៣០នាទី ព្រឹក និងត្រូវបញ្ចប់ត្រឹមម៉ោង ១១ ព្រឹក។
- The burning of bushes in the farm shall start at 9:30 am at the latest and ends at 11am.

- សមាជិកសហគមន៍ដែលដល់ពេលកំណត់ត្រូវដុតព្រៃក្នុងចម្ការ ត្រូវរៀបចំចម្ការនោះឲ្យបានរួចរាល់មុនម៉ោង ៩ និង ៣០ នាទីព្រឹក បើយឺតជាងនេះ សមាជិកសហគមន៍ ត្រូវណាត់ពេលដុតព្រៃក្នុងចម្ការឡើងវិញទៅតាមកម្មវិធីរបស់ ភាគីក្រុមហ៊ុន។
- Community members who have farmland must burn the bushes on time and prepare the farmland to be ready for burning before 9:30 am, and if it is late, the community members have to reschedule the burning according to the program of **the Company Party**.



**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

**CHAN Sophoap**, Translation PM  **LIM Kruy**, CEO

- ភាគីក្រុមហ៊ុនអនុញ្ញាតឱ្យធ្វើការដុតព្រៃក្នុងចម្ការបានតែ ០២ (ពីរ) កន្លែងតែប៉ុណ្ណោះក្នុងមួយថ្ងៃ។
- Company Party agrees for burning the bushes only 2 (two) places in a day.
- ដរាបណារាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតិឱ្យអនុវត្តន៍ នោះការដុតព្រៃក្នុងចម្ការអនុញ្ញាតបានចំពោះចម្ការចាស់តែ ប៉ុណ្ណោះ និងមិនអនុញ្ញាតឱ្យដុតព្រៃរានដីថ្មីធ្វើជាចម្ការទេ។
- As long as the Royal Government of Cambodia authorizes the practice, the burning farm bushes are allowed only on existing farmland, not on new clearing land.

១.៦.- ផ្លូវចូលទៅដីចម្ការរបស់សហគមន៍ ដែលត្រូវឆ្លងកាត់តាមផ្លូវចូលរបស់ក្រុមហ៊ុន

**1.6. Access road to the community farmland passes through the access road of the company**

- ក្រុមហ៊ុនមិនមានគោលការណ៍បិទផ្លូវទេ ដូច្នេះក្រុមហ៊ុនអនុញ្ញាតិឱ្យសហគមន៍អាចធ្វើការចេញចូលដោយសេរី គ្រាន់តែមានការត្រួតពិនិត្យ និងសួរនាំព័ត៌មានមួយចំនួនប៉ុណ្ណោះ សម្រាប់ការការពារសុវត្ថិភាព។

The company does not have a roadblock policy, so the company allows the community to enter and exit freely, with only checking and asking some information for security protection.

១.៧.- ការបន្តអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកតំណាងក្រុមហ៊ុន និងសហគមន៍ ក្នុងករណីមានការផ្លាស់ប្តូរ

**1.7.- Continuation of agreement implementation between company and community in case of change representatives**

- ភាគីក្រុមហ៊ុនយល់ព្រមថា ក្នុងករណីមានការផ្លាស់ប្តូរអ្នកតំណាងក្រុមហ៊ុននាថ្ងៃអនាគត អ្នកតំណាងក្រុមហ៊ុនថ្មីត្រូវគោរពតាមកិច្ចព្រមព្រៀងនេះ។
- **The Company Party** agrees that in the event of a change of Company Representatives in the future, the new Company Representative shall abide by this Agreement.



first class
in pursuit of speed and quality

**First-Class Solutions Ltd.,** registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **IM Kruy**, CEO

- ភាគីសហគមន៍យល់ព្រមថា ក្នុងករណីមានការផ្លាស់ប្តូរអ្នកតំណាងសហគមន៍នាថ្ងៃអនាគត អ្នកតំណាង តំណាងសហគមន៍ថ្មីត្រូវតែគោរពតាមកិច្ចព្រមព្រៀងនេះ។

  **The Community Party** agrees that in the event of a change in future community representatives, the new community representatives must abide by this agreement.

**ប្រការ ២.- ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ**

**Article 2.- Annexes to this Agreement**

ភាគីសហគមន៍ និងភាគីក្រុមហ៊ុន យល់ព្រម និងឯកភាពគ្នាទទួលយកនូវឯកសារមួយចំនួនដែលជាឧបសម្ព័ន្ធនៃ កិច្ចព្រមព្រៀងសះជា ដូចខាងក្រោមនេះ៖

The **Community Party** and the **Company Party** agree to recognize the following documents as annexes in the agreements:

- បញ្ជីរាយនាមម្ចាស់ចម្ការតាមដងអូរ និងទិន្នន័យទំហំដីចម្ការតាមដងអូររបស់សហគមន៍ភូមិពូលុ ជាមួយក្រុមហ៊ុន សេដ្ឋិកុលា
- The list of claimed farmland owners and data on the size of the farm along the stream of Pu Lu village community with Sethikula company
- ផែនទីបង្ហាញទីតាំងដីចម្ការតាមដងអូររបស់សហគមន៍ភូមិពូលុ ជាមួយក្រុមហ៊ុនសេដ្ឋិកុលា
- Map shows the location of the farms along the stream of Pu Lu village community with Sethikula company
- លិខិតប្រគល់សិទ្ធិជាអ្នកតំណាងលើករណីដីចម្ការតាមដងអូររបស់ភូមិពូលុ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧
- Letter authorization on the community representatives for the conflict case on the land along the stream dated 17/11/2017.
- ឯកសារមួយចំនួនផ្សេងទៀតដែលមានទំនាក់ទំនង ឬពាក់ព័ន្ធនឹងករណីដីចម្ការតាមដងអូររបស់ភូមិពូលុ និងក្រុម ហ៊ុនសេដ្ឋិកុលា។
- Other documents related or connected with the conflict case on land along the stream of Pu Lu village community with Sethikula company.

**ប្រការ ៣.- ភារកិច្ច និងការធានារបស់ភាគីសហគមន៍**

**Article 3.- Obligations and Warranties of the Community Party**

៣.១- ភាគីសហគមន៍ ត្រូវធានាថាខ្លួនមានសិទ្ធិស្របច្បាប់នៅក្នុងការចុះកិច្ចព្រមព្រៀងនេះ និងមានកាតព្វកិច្ចធានា ថាមិនធ្វើការរំខាន ចំពោះករណីដែលបានដោះស្រាយរួចហើយរបស់ខ្លួនចំពោះភាគីក្រុមហ៊ុនម្តងទៀតទេ។

ទំ ៨ / ១៦



First-Class Solutions Ltd., registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

ហ្វឺស-ក្លាស សឹលូសិន ឯ.ក
FIRST-CLASS SOLUTIONS

CHAN Sopheap, Translation PM    LIM Kruy, CEO

3.1- **The Community Party** shall warrant that it has the legal right to enter into this Agreement and is obliged to ensure that it will not cause further disturbance to **the Company Party** for the case solved.

៣.២- ភាគីសហគមន៍ធានាថាខ្លួននឹងប្រាប់ ឬឲ្យលាំទៅសមាជិកសហគមន៍របស់ខ្លួន និងកូនចៅជំនាន់ក្រោយរបស់ សហគមន៍ឲ្យគោរពនូវប្រការនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

3.2- **The Community Party** warrants that it will inform its community members and the younger generations of the community and cause them to honor all the provisions of this Agreement.

៣.៣- ភាគីសហគមន៍មានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឲ្យស្រប តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

3.3- **The Community Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.

៣.៤- ភាគីសហគមន៍ យល់ព្រមគោរពតាមច្បាប់របស់ក្រសួងពាក់ព័ន្ធក្នុងការប្រើប្រាស់ដីចម្ការតាមដងអូររបស់ សហគមន៍។

3.4- **The Community Party** agrees to abide by the law of the relevant ministries in the use of the farm land along the stream of the community.

**ប្រការ ៤.- កាតព្វកិច្ច និងការធានារបស់ភាគីក្រុមហ៊ុន**

**Article 4.- Obligations and Warranties of the Company Party**

៤.១- ភាគីក្រុមហ៊ុន សន្យានឹងមិនធ្វើការឈូសឆាយ ឬប៉ះពាល់លើដីចម្ការតាមដងអូរទាំងអស់ ដូចមានចែងក្នុង ប្រការ ១ និងប្រការ ២ ខាងលើទៅថ្ងៃអនាគតនោះទេ។

4.1- **The Company Party** covenants that it will not clear or do anything to the land along the stream as stated in Article 1 and 2 above in the future.

៤.២- ភាគីក្រុមហ៊ុនធានាថាទោះបីថ្ងៃក្រោយមានការប្រែប្រួលអ្នកដឹកនាំ ឬធ្វើការផ្ទេរនៅសិទ្ធិលើការគ្រប់គ្រងនៃដី សម្បទាននេះទៅឲ្យក្រុមហ៊ុនផ្សេង ឬតតីយជនក៏ដោយ ក្រុមហ៊ុននឹងបញ្ចូលនូវឯកសារនៃកិច្ចព្រមព្រៀង នេះទៅក្នុងកិច្ចសន្យាសម្បទានបន្ត ឬកិច្ចសន្យាលក់សិទ្ធិសម្បទាននោះ ឬកិច្ចសន្យាផ្សេងៗរបស់ក្រុមហ៊ុន ។

4.2- **The Company Party** warrants that regardless of any future change in the management or the transfer of management rights on the concession to other companies or third parties, the company will incorporate this agreement document in the transferred Concession Agreement or the contract for the sale of the concession rights or any contracts of the company.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that the translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of its contents herein.*

**CHAN Sophea**p, Translation PM, Kruy, CEO

៤.៣- ភាគីក្រុមហ៊ុនមានកាតព្វកិច្ចអនុវត្តនូវគ្រប់ប្រការទាំងអស់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឱ្យស្រប តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

4.3- **The Company Party** is obliged to carry out all the provisions of this Agreement in accordance with the laws of the Kingdom of Cambodia.

**ប្រការ ៥.- ការមិនគោរព ឬបំពានកិច្ចព្រមព្រៀង**

**Article 5.- Default or Violations of Agreement**

៥.១- ក្នុងករណីភាគីសហគមន៍បានបំពាន ឬមិនគោរពតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ភាគីសហគមន៍សុខចិត្ត ទទួលខុសត្រូវតាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា ដែលមានជាធរមាន។

5.1- In the event that the **Community Party** has violated or failed to comply with the provisions of this Agreement, the **Community Party** undertakes to be held responsible before the applicable laws of the Kingdom of Cambodia.

៥.២- ក្នុងករណីភាគីក្រុមហ៊ុនបានបំពាន ឬមិនគោរពតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ភាគីក្រុមហ៊ុនសុខចិត្តទទួល ខុសត្រូវតាមច្បាប់នៃព្រះរាជណាចក្រកម្ពុជា ដែលមានជាធរមាន។

5.2- In the event that **the Company Party** has violated or failed to comply with the provisions of this Agreement, **the Company Party** undertakes to be held responsible before the applicable laws of the Kingdom of Cambodia.

៥.៣- ក្នុងករណីដែលភាគីណាមួយដែលបំពាននៃកិច្ចព្រមព្រៀងនេះ ហើយបណ្តាលឱ្យមានការខូចខាតកើតឡើង ទាំងផ្នែករូបីយវត្ថុ (សាច់ប្រាក់ឬ លុយ) ផ្លូវចិត្ត និងផលប្រយោជន៍ផ្សេងៗ របស់ភាគីម្ខាងទៀតនោះ ភាគី ដែលរំលោភកិច្ចព្រមព្រៀងនេះនឹងទទួលខុសត្រូវចំពោះមុខច្បាប់។

5.3- In the event that any party violates this Agreement resulting in damage both monetarily (cash or money) and emotionally and to other interests of the other party, the violating party shall assume legal responsibility.

៥.៤- ភាគីណាមួយក៏ដោយដែលរំលោភបំពាននៃកិច្ចព្រមព្រៀងនេះ ត្រូវធានាសងចំពោះការខូចខាតទាំងឡាយ ដែល កើតមានចំពោះភាគីម្ខាងទៀត លើរាល់ការចំណាយនៃការខូចខាត ថ្លៃសេវាផ្សេងៗ រួមទាំងថ្លៃមេធាវី ដែលអាចកើតមានឡើងដោយសារការរំលោភបំពានកិច្ចព្រមព្រៀងនេះ។



first class
**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia
#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*
Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document but does not establish the authenticity of the original document or the correctness of the contents herein.*
CHAN Sophea, Translation PM    LIM Krui, CEO
FIRST-CLASS SOLUTIONS

5.4- Any party that violates this Agreement shall be liable for paying damages incurred by the other party for all costs of damages, fees including attorneys' fees that may incur as a result of the breach of this Agreement.

## ប្រការ ៦.- ការអនុវត្តកិច្ចព្រមព្រៀង ការរំលាយកិច្ចព្រមព្រៀង វិសោធនកម្ម ឬកែប្រែកិច្ចព្រមព្រៀង និង នីតិវិធីនៃការដោះស្រាយវិវាទសម្រាប់ការរំលោភបំពានលើការមិនគោរពកិច្ចព្រមព្រៀង

## Article 6.- Implement agreements, dissolve agreements, amend or change agreements and procedures for resolving disputes for violation or breach of the Agreement

៦.១- ភាគីទាំងពីរត្រូវសហការគ្នាអនុវត្តកិច្ចព្រមព្រៀងនេះឲ្យបានទៀងទាត់ ពេញលេញ និងត្រឹមត្រូវ ប្រកបដោយបរិយាកាសស្មោះត្រង់ និងទុកចិត្តគ្នាទៅវិញទៅមក។ ករណីភាគីណាមួយខកខានមិនបានអនុវត្ត ឬអនុវត្តមិនត្រឹមត្រូវ ឬមិនពេញលេញតាមកិច្ចព្រមព្រៀង នោះភាគីដែលរងគ្រោះអាចតម្រូវឲ្យភាគីម្ខាងទៀត អនុវត្តឲ្យបានត្រឹមត្រូវឡើងវិញ។

6.1- **Both parties** shall cooperate to implement the agreement regularly, fully and correctly in accordance with the agreement in an honesty atmosphere and mutual trust. In the event that one party fails to implement or has improperly or incompletely implemented the agreement, the affected party may require the violating party to correct it.

៦.២- ក្នុងករណីមានការអនុគ្រោះពីភាគីម្ខាង ដល់ភាគីម្ខាងទៀត ក្នុងការមិនអនុវត្តសិទ្ធិណាមួយរបស់ខ្លួន ដែលកើតចេញពីកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវបានបកស្រាយថាភាគីនោះបោះបង់សិទ្ធិរបស់ខ្លួនឡើយ ។

6.2 - In the event of any party giving favors to the other party in the exercise of any of its rights arising from this Agreement shall not be construed as a waiver of that right.

- រាល់ការព្រមព្រៀងមុនពេលមានការសម្រុះសម្រួល រវាងភាគីទាំងពីរ ទោះដោយផ្ទាល់មាត់ក្តី ជាលាយលក្ខអក្សរក្តី ដែលមានខ្លឹមសារផ្ទុយនឹងកិច្ចព្រមព្រៀងនេះ ត្រូវទុកជាមោឃៈ និងមិនអាចអនុវត្តបាន ។
- Any agreements prior to the mediation between **both parties**, whether oral or written, that is contrary to this agreement shall be null and void.
- រាល់ការកែខ្លឹមសារផ្សេងៗ នៃកិច្ចព្រមព្រៀងនេះ នឹងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់បាន លុះត្រាតែបានធ្វើឡើងជាលាយលក្ខអក្សរ និងចុះហត្ថលេខា ឬផ្តិតមេដៃព្រមព្រៀង ដោយភាគីទាំងពីរ។



first class
In pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document but does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sophea, Translation PM — Kruy, CEO

- Any amendment to the terms of this Agreement shall be legally binding only if it is in writing, signed or thumb printed by **both parties**.
- ក្នុងករណីប្រការណាមួយ ឬខ្លឹមសារណាមួយនៃកិច្ចព្រមព្រៀងត្រូវបានច្បាប់ចាត់ទុកជាមោឃៈ នោះប្រការ ឬ ខ្លឹមសារដ៏ទៃទៀតនៃកិច្ចព្រមព្រៀងនេះនៅតែមានអានុភាពអនុវត្តតាមផ្លូវច្បាប់ដដែល ។
- In the event that any provision or content of this agreement is invalidated by law, the other provisions or content of this agreement shall remain in force.

៦.៣- បើមានហេតុការណ៍អ្វីកើតឡើងជាយថាហេតុដោយពុំបានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីណាមួយ ឬភាគី ទាំងពីរត្រូវកោះប្រជុំដើម្បីពិភាក្សាគ្នា ឬកែប្រែប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះតាមស្មារតីយោគយល់គ្នា។

6.3- If any eventual event arises that is not stated in this agreement, either or **both parties** shall convene a meeting to discuss or amend any provision of this agreement in a spirit of mutual understanding.

៦.៤- ករណីមានវិវាទបណ្តាលមកពីការអនុវត្តកិច្ចព្រមព្រៀងនេះ ឬក្នុងករណីភាគីណាមួយមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងនេះ **ភាគីទាំងពីរ** ត្រូវធ្វើការចរចារគ្នាឱ្យអស់លទ្ធភាពជាមុនសិនមុននឹងប្តឹងទៅតុលាការ ។ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ បើមិនអាចដោះស្រាយវិវាទបានដោយជោគជ័យទេនោះ **ភាគីទាំងពីរ** អាចធ្វើការដោះស្រាយតាមរយៈអ្នកសម្រុះសម្រួលឯករាជ្យណាមួយ ឬយន្តការណាមួយតាមផ្លូវច្បាប់ជាធរមាន បើមិនអាចដោះស្រាយវិវាទបានដោយជោគជ័យទេ ភាគីរងគ្រោះ ឬភាគីម្ខាងទៀតមានសិទ្ធិប្តឹងរំលាយកិច្ចព្រមព្រៀងនេះបានតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

6.4- In the event of a dispute arising out of the implementation of this agreement or in the event that either party fails to perform the obligations under this agreement, both parties shall first negotiate to the fullest extent before filing a lawsuit to the court. If the dispute cannot be resolved successfully within 60 (sixty) days, both parties can resolve it through any independent mediator or any legal mechanism in force. The affected party or the other party has the right to dissolve this agreement through the courts of the Kingdom of Cambodia.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 2021
*This is to certify that this translation accurately corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM **Kruy**, CEO

៦.៥- ការជូនដំណឹងជាផ្លូវការរវាងភាគីទាំងពីរអាចធ្វើ ឬត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមគ្រប់រូបភាព និងអាចបញ្ជូនទៅអាស័យដ្ឋានរបស់ភាគីនីមួយៗ ឬអាស័យដ្ឋានដូចមានបញ្ជាក់ខាងលើ ឬអាចបញ្ជូនតាមរយៈភ្នាក់ងាររត់សំបុត្រ ឬសារអេឡិចត្រូនិច ឬតាមទូរស័ព្ទក៏បាន ។

6.5- Formal notification between the **two parties** may be made in writing in any form and may be sent to the address of each party or to the address as specified above, or may be sent by courier or e-mail or telephone.

៦.៦- ភាគីអាចរំលាយកិច្ចព្រមព្រៀងសះជានេះបានតាមការព្រមព្រៀងរបស់ភាគីទាំងពីរ។

6.6- The parties may dissolve this settlement agreement as agreed by both parties.

**ប្រការ ៧.- ឆន្ទៈ និងសមត្ថភាពរបស់ភាគី**

**Article 7.-Willingness and Capacity of Parties**

៧.១- ភាគីទាំងពីរមានឆន្ទៈរួមគ្នាដើម្បីបង្កើតកិច្ចព្រមព្រៀងនេះឡើងដោយគ្មានការបង្ខិតបង្ខំ ឬការគំរាមកំហែងពីភាគីណាមួយនោះឡើយ។

7.1- Both parties are willing to enter into this Agreement without coercion or threat from any party.

៧.២- ភាគីទាំងពីរ បានអាន បានស្ដាប់យល់ និងមានសមត្ថភាពយល់ដឹងនូវខ្លឹមសារបានគ្រប់ប្រការទាំងអស់ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដោយសន្យាថានឹងអនុវត្តគ្រប់ប្រការទាំងអស់នៃកិច្ចព្រមព្រៀងនេះឲ្យបានត្រឹមត្រូវ និងស្របតាមច្បាប់។

7.2- Both parties have read, been read out and have the ability to fully understand all the provisions hereof, undertaking to duly carry out all the provisions of this Agreement in accordance with the law.

**ប្រការ ៨.- ច្បាប់នៃកិច្ចព្រមព្រៀង និង ភាសាដែលប្រើក្នុងកិច្ចព្រមព្រៀង**

**Article 8.- Counterpart, language used in the agreement**

៨.១- ភាគីទាំងអស់ រួមទាំងអ្នកសម្រុះសម្រួល ឯកភាពគ្នាទទួលយកច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាច្បាប់នៃការ អនុវត្ត និងការបកស្រាយកិច្ចព្រមព្រៀងនេះជាគោល។

8.1- All parties agree that the laws of the Kingdom of Cambodia shall be the principal laws governing the performance and interpretation of this Agreement.

៨.២- កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាខ្មែរ និងមានការបកប្រែជាភាសាអង់គ្លេស នៅក្នុងភាសានីមួយៗ និង គ្រប់ច្បាប់ទាំងនេះត្រូវចាត់ទុកជាលិខិតតូបករណ៍ ឬលិខិតផ្លូវការតែមួយ



**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

first class
in pursuit of speed and quality

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(IMG2021)

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document but does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS

CHAN Sopheap, Translation PM, ... Kruy, CEO

និង ដូចៗគ្នា។ ក្នុងករណីមានភាព ខុសគ្នារវាងអត្ថបទជាភាសាខ្មែរ និងអត្ថបទជាភាសាអង់គ្លេស ភាសាខ្មែរត្រូវប្រើជាអត្ថបទគោលក្នុងការបក ស្រាយកិច្ចព្រមព្រៀងនេះ។

8.2- This agreement shall be made in Khmer and accompanied with English translation in each language, all of which taken together shall constitute one and the same instrument or official instrument. In the event of any inconsistency between Khmer and English versions of the Agreement, the Khmer version of the Agreement shall be the prevailing text in the interpretation of this Agreement.

## ប្រការ ៩.- អវសានប្បញ្ញត្តិនៃកិច្ចព្រមព្រៀង

## Ariticle 9.- Final provisions of the Agreement

៩.១- កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និង អង់គ្លេស ចំនួន ០៥ (ប្រាំ) ច្បាប់ដើមក្នុងមួយភាសា ដែលមានតម្លៃគតិយុត្តស្មើគ្នា និងដូចគ្នា ហើយត្រូវរក្សាទុកនៅភាគីសហគមន៍ ចំនួន ០១(មួយ)ច្បាប់ដើម, ភាគី ក្រុមហ៊ុន ចំនួន០១ (មួយ)ច្បាប់ដើម អ្នកសម្រុះសម្រួល ចំនួន០១(មួយ)ច្បាប់ដើម តម្កល់នៅ សាលាស្រុក ពេជ្រាដា ចំនួន ០១(មួយ)ច្បាប់ និង ០១ (មួយ)ច្បាប់ដើម សម្រាប់ភាគីសហគមន៍រៀបចំបែបបទ ស្នើសុំចុះបញ្ជីដីសម្ហូហភាពរបស់សហគមន៍ភូមិពូលុ។

9.1- This Agreement is made in Khmer and English into 05 (five) originals of the same and equal legal force and effect and 01 (one) original of which shall be retained with the Community Party, the Company Party, mediator, filed at Pichreada district Hall and with the Community Party for completion of the application form for registration of Pu Lu village communal land, respectively.

៩.២- គ្រប់ភាគីទាំងអស់ ត្រូវបានចងកាតព្វកិច្ច ចំពោះលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនះ និងត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំលើកិច្ចព្រមព្រៀង ដើម្បីជាសក្ខីភាព ឬការបញ្ជាក់នៃការចូលរួមរបស់ខ្លួន ។

9.2- All parties are bound by the terms of this Agreement and shall affix their signatures or right thumbprints on the Agreement as testimony or in the acknowledgement of their acceptance.

៩.៣-កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនេះតទៅ។

9.3- This agreement is effective from the date of signing or affixing thumbprints.



first class
in pursuit of speed and quality

**First-Class Solutions Ltd.**, registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

FIRST-CLASS SOLUTIONS LTD

**CHAN Sopheap**, Translation PM & **LIM Kruy**, CEO

ភាគីសហគមន៍

**Community party**

ភាគីក្រុមហ៊ុន

**Company Party**

| | | | |
|---|---|---|---|
| លោក មើល ង៉ែវ | លោកស្រី ពឿល នៀន | លោក ម៉ាលី គីម | [redacted] |
| **Mr. Moeurl Ngev** | **Mrs. Pyoeurl Nien** | **Mr. Maly Kim** | ក្រុមហ៊ុនសេដ្ឋកុលា |
| | | | **Sethikula Company** |

មេធាវីរបស់ភាគីសហគមន៍

**Attorney at law of the community**

| | |
|---|---|
| ធឿង ពុទ្ធារិទ្ធ | រុន សារាយ |
| **Thoeung Puthearith** | **Run Saray** |

សាក្សី

**Witnesses**

តំណាងចាស់ទុំភូមិពូលូ

**Representatives of the elders Pu Lu**

តំណាងអាជ្ញាធរស្រុកពេជ្រាដា

**Pichreada District Authority**

| | | |
|---|---|---|
| ប្រប់ ម៉ាលី | ខែល ស្រេត | ខាំ ផងជា |
| **Brorb Maly** | **Khel Sret** | **Kham Phangchea** |



first class
in pursuit of speed and quality

**First-Class Solutions Ltd.,** registered under No. Co. 13113/09P with the Ministry of Commerce of the Kingdom of Cambodia

#12 Street 222, Phnom Penh, Cambodia
+855 23 214 142 / 12 925 789 / 18 960 751 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
*(IMG2021)*

Phnom Penh, September 17, 2021
*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

**CHAN Sophea**p, Translation PM ... Kruy, CEO

| អ្នកសម្រុះសម្រួល<br>**Mediator** | បានឃើញ និងបញ្ជាក់ថា<br>**Seen and certified that**<br>ភាគីទាំងពីរពិតជាបានព្រមព្រៀងគ្នាតាមកិច្ចព្រមព្រៀង<br>និងបានផ្តិតមេដៃចំពោះមុខពិតប្រាកដមែន។<br>Both Parties have agreed to the Agreement and affixed their thumbprints in my presence.<br>អាជ្ញាធរឃុំប៊ូស្រា<br>**Authority of Busra commune** |
|---|---|
| លោក ប៉ុច សោភ័ណ<br>**Mr. Poch Sophorn**<br>ក្រុមសម្រុះសម្រួលឯករាជ្យ<br>Independent Mediation Team | យើត_សារីន |





Phnom Penh, September 17, 2021

*This is to certify that this translation correctly corresponds to all the essential particulars of the attached document. It does not establish the authenticity of the original document or the correctness of the contents herein.*

**CHAN Sopheap**, Translation PM **[illegible] Kruy**, CEO